ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន



# ផលិតកម្មដំណាំស្រូវប្រកបដោយនិរន្តរភាព

## Sustainable Rice Platform ( SRP )

## ផ្នែកទី ៤, ៥ និង៦

**រៀបរៀងដោយ ៖ នាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម**

# ផ្នែកទី៤ ការគ្រប់គ្រងសារធាតុចិញ្ចឹម



ស្តង់ដា SRP លើការគ្រប់គ្រងសារធាតុចិញ្ចឹមមាន ៣ លក្ខខណ្ឌតម្រូវគឺ៖

- R15. ការគ្រប់គ្រងសារធាតុចិញ្ចឹម (សរីរាង្គ& អសរីរាង្គ)
- R16. ការប្រើប្រាស់ជីសរីរាង្គ
- R17. ការប្រើប្រាស់ជីអសរីរាង្គ

# ផ្នែកទី៤ ការគ្រប់គ្រងសារធាតុចិញ្ចឹម

## តើហេតុអ្វីបានជាការបានការគ្រប់គ្រងសារធាតុចិញ្ចឹមបានត្រឹមត្រូវមានសារសំខាន់?

- ធានាបាននូវការប្រើប្រាស់ធាតុចូលដ៏ប្រសើរបំផុតក្នុងការដាំដុះដំណាំ។
- អាចបង្កើនផលិតភាពតាមរយៈការកាត់បន្ថយថ្លៃដើមផលិតកម្ម។



# មេរៀនទី២

# ការគ្រប់គ្រងសារធាតុចិញ្ចឹម (ត)

ចំណាំ៖ មុខងារសំខាន់ៗរបស់ ជី N P K

- អាសូត (N) ធ្វើឱ្យស្លឹកពណ៌បៃតងចាស់
- ផូស្វាយ (P) ជំនួនដល់ ឬស និងធ្វើឱ្យស្រូវបែកគុម្ពល្អ
- ប៉ូតាស្យូម (K) ធ្វើឱ្យដើមស្រូវរឹងមាំ និងដាក់គ្រាប់ពេញណែនល្អ







## R15. ការគ្រប់គ្រងសារធាតុចិញ្ចឹម (សរីរាង្គ& អសរីរាង្គ)

| លក្ខខណ្ឌតម្រូវ |
|---|
| ការគ្រប់គ្រងសារធាតុចិញ្ចឹមប្រកបដោយប្រសិទ្ធភាពបានអនុវត្ត និងកត់ត្រាវិធានការសម្រាប់គ្រប់គ្រងសារធាតុចិញ្ចឹមដោយប្រសិទ្ធភាពរួមមាន៖<br>១. កំណត់ពេលវេលាប្រើប្រាស់ជី (សរីរាង្គ(ធម្មជាតិ) ឬ/និងជីគីមី (N P ឬ/និង K) ទៅតាមតម្រូវការរបស់ដំណាំ តាមអនុសាសន៍នៃការប្រើប្រាស់ជីក្នុងតំបន់ ឬការណែនាំរបស់ផលិតផល (ប្រសិនបើមាន)<br>២. បរិមាណជី (សរីរាង្គ/គីមី (N, P, K) ដែលប្រើគឺតាមជីជាតិដី និងទិន្នផលដែលចង់បាន, តាមអនុសាសន៍នៃការប្រើប្រាស់ជី និងការណែនាំរបស់ផលិតផល (ប្រសិនបើមាន)។<br>៣. ការធ្វើឱ្យប្រសើរឡើងនូវជីជាតិដីតាមបែបប្រព័ន្ធធម្មជាតិ (ឧ. ការដាំដំណាំបង្វិល, ការដាំដំណាំឆ្លាស់ និងការដាំដំណាំគម្របដី) ត្រូវបានអនុវត្ត។ |

| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) កសិករអនុវត្តតាមវិធានការទាំងបីដែលបានរៀបរាប់។ | ៦ |
| b) កសិករអនុវត្តតាម ២វិធានការក្នុងចំណោម៣វិធានការដែលបានរៀបរាប់។ | ៤ |
| c) កសិករអនុវត្តតាម ១វិធានការក្នុងចំណោម៣វិធានការដែលបានរៀបរាប់។ | ២ |
| d) កសិករមិនអនុវត្តតាមចំណុចណាមួយដែលបានរៀបរាប់ | 0 |

## R15. ការគ្រប់គ្រងសារធាតុចិញ្ចឹម (សរីរាង្គ& អសរីរាង្គ)

### Simple method to measure soil nutrition level..

**Soil Test Kit**





*40% input cost has been decreased after using the soil test kit - BRIA Indonesia, GIZ project*

**Leaf Color Chart**



# R15. ការគ្រប់គ្រងសារធាតុចិញ្ចឹម (សរីរាង្គ& អសរីរាង្គ)

## New technology to measure soil nutrition level..

**Portable Soil Spectrum Meter**



**SoilCares Scanner from Holland Green Tech (HGT)**

- Portable devise that uses near-infrared technology and a connection to SoilCares Global Soil Database to accurately determine the soil's properties
- Measures N, P, K, and Cation Exchange Capacity (CEC) in soil and determines the temperature, pH, and OM level
- It connects to your smartphone via Bluetooth and provides you with a soil status report and fertilization advise.




(Rikolto, 2018)

## R16. ការប្រើប្រាស់ជីសរីរាង្គ

| លក្ខខណ្ឌតម្រូវ | កម្រិតនៃការអនុវត្តន៍តាម | |
|---|---|---|
| សារធាតុសរីរាង្គ (លាមកសត្វ ជីស្រស់ គម្របដី ចំបើង) ត្រូវបានប្រើប្រាស់ជាជីប្រសិនបើលក្ខខណ្ឌអំណោយផល។ លក្ខខណ្ឌអំណោយផលមានដូចជា៖<br><br>១. វាអាចប្រើប្រាស់នៅលើស្រែមិនលិចទឹកក្នុងទម្រង់ជាជីកំប៉ុស្តិ៍ ឬរលួយ<br>២. ទុកពេលវេលាគ្រប់គ្រាន់សម្រាប់វារលួយជាកំប៉ុស្តិ៍មុនទឹកជំនន់។<br>៣. វាមានបរិមាណគ្រប់គ្រាន់ និងរកបានក្នុងមូលដ្ឋាន (ចំងាយមិនលើសពី ៥០ គីឡូម៉ែត្រ) ។ | a) កសិករប្រើប្រាស់សម្ភារសរីរាង្គ ជាជីទៅតាមលក្ខខណ្ឌទាំងបីដែលបានថែង។ | ៣ |
| | b) កសិករប្រើប្រាស់សម្ភារសរីរាង្គជាជីទៅតាមលក្ខខណ្ឌ ១ និង ២ ប៉ុណ្ណោះ។ | ២ |
| | **c) កសិករមិនប្រើសម្ភារសរីរាង្គជាជីទេ ពីព្រោះវាមិនត្រូវនឹងលក្ខខណ្ឌមួយ រឺច្រើនដែលបានរៀបរាប់។** | ២ |
| | d) កសិករមិនប្រើសម្ភារសរីរាង្គជាជីទេ ទោះបីជាកសិករយល់ដឹងពីលក្ខខណ្ឌទាំងនោះ និងត្រូវនឹងលក្ខខណ្ឌទាំងនោះក៏ដោយ។ | ១ |
| | e) កសិករភ្ជួរលុបសម្ភារសរីរាង្គចូលទៅក្នុងដីដែលលិចទឹក។ | ០ |

## R16. ការប្រើប្រាស់ជីសរីរាង្គ

**Why decomposition process of organic matter has to be done in non-flooded field?**




Mechanism of Methane emissions from Paddy rice field in Japan

## R17. ការប្រើប្រាស់ជីអសរីរាង្គ

| លក្ខខណ្ឌតម្រូវ |
|---|
| ជីអសរីរាង្គអាចត្រូវបានប្រើប្រាស់តែក្នុងករណីដែលជីទាំងនោះត្រូវបានចុះបញ្ជីត្រឹមត្រូវ និងជាជីមកពីប្រភពគួរជាទីទុកចិត្តប៉ុណ្ណោះ។ |



| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) មិនមានការប្រើប្រាស់ជីអសរីរាង្គ (គីមី)។ | ៣ |
| b) កសិករប្រើប្រាស់ជីអសរីរាង្គដែលត្រូវបានចុះបញ្ជីត្រឹមត្រូវ និងជាជីមកពីប្រភពមិនក្លែងបន្លំ។ | ៣ |
| c) កសិករប្រើប្រាស់ជីអសរីរាង្គដែលមិនបានចុះបញ្ជីត្រឹមត្រូវ និងមកពីប្រភពក្លែងបន្លំ។ | ០ |

# ផ្នែកទី៥

## ការគ្រប់គ្រងសមាសភាពចង្រៃ (IPM)

ស្តង់ដា SRP លើការគ្រប់គ្រងសមាសភាពចង្រៃបែងចែកជា ៦ លក្ខខណ្ឌតម្រូវគឺ៖

- R18.1. ការគ្រប់គ្រងស្មៅចង្រៃ
- R18.2. ការគ្រប់គ្រងសត្វល្អិតចង្រៃ
- R18.3. ការគ្រប់គ្រងជំងឺ
- R18.4. ការគ្រប់គ្រងសិប្បីសត្វ (ពពួកខ្យង)
- R18.5. ការគ្រប់គ្រងសត្វកណ្តុរ
- R18.5. ការគ្រប់គ្រងសត្វបក្សី



# ផ្នែកទី៥

## ការគ្រប់គ្រងសមាសភាពចង្រៃ (IPM)

### ហេតុអ្វីបានជាការគ្រប់គ្រងសមាសភាពចង្រៃមានសារៈសំខាន់?

- ជួយគ្រប់គ្រងសមាសភាពចង្រៃ (សត្វល្អិត ជំងឺ ស្មៅ ជាដើម) យ៉ាងមានប្រសិទ្ធភាព ដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ផលិតភាពស្រូវប្រសិនបើមិនបានដោះស្រាយ។
- រាប់បញ្ចូលទាំងវិធានការកំចាត់សមាសភាពចង្រៃ និងការការពារក្នុងកំឡុងពេលវដ្តដំណាំទាំងមូល។

### តើអ្វីជាគោលបំណងរបស់ IPM?

**ដើម្បីគ្រង់សមាភាពចង្រៃ និងផលប៉ះពាល់ផ្សេងទៀត**ដូចជា កាត់បន្ថយថ្លៃដើម ការពារបរិស្ថាន ការកាត់បន្ថយការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត,

**ដើម្បីគ្រប់គ្រងសមាសភាពចង្រៃប្រកបដោយប្រសិទ្ធភាព សេដ្ឋកិច្ចនិង សុវត្ថិភាព៖** សម្រាប់អ្នកប្រើប្រាស់ សហគមន៍ និងបរិស្ថាន។



## R18.1. ការគ្រប់គ្រងស្មៅចង្រៃ

| លក្ខខណ្ឌតម្រូវ៖ កសិករអនុវត្តតាមគោលការណ៍ IPM និងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម |
|---|
| ១. វិធីសាស្ត្របង្ការកុំឱ្យមានស្មៅចង្រៃត្រូវបានប្រើ មុនពេលពិចារណារកវិធីសាស្ត្រកម្ចាត់ផ្សេងទៀត ។ |
| ២. ថ្នាំសំលាប់ស្មៅត្រូវបានប្រើលុះត្រាតែការប្រើវិធីសាស្ត្រកម្ចាត់ស្មៅចង្រៃ (ឧ.ការកម្ចាត់ដោយដៃ ឬដោយមេកានិក) មិនមានប្រសិទ្ធភាព ហើយស្មៅមានភាពធ្ងន់ធ្ងរ ត្រូវបានគេរំពឹងថានឹងបង្កឱ្យមានការខូចខាត ឬការបាត់បង់ច្រើនគួរឱ្យកត់សម្គាល់។ |
| ៣. ការជ្រើសរើសថ្នាំសំលាប់ស្មៅគឺសមស្របតាមការណែនាំរបស់រដ្ឋាភិបាល ហើយបានចុះបញ្ជីសម្រាប់ប្រើលើស្រូវ, បានមកពីប្រភពមិនក្លែងក្លាយ និងមិនមាននៅក្នុងបញ្ជីអន្តរជាតិដូចខាងក្រោម៖<br>✓ ការបំពុលដោយសារធាតុគីមីសរីរាង្គ (POP) ដូចមាននៅក្នុងអនុសញ្ញាស្តុកខុម (Stockholm Convention)<br>✓ 1A ឬ B1 ក្នុងចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក<br>✓ ឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញារ៉ូទ័រដាំ (Rotterdam Convention) |
| ៤. ការប្រើប្រាស់ថ្នាំកម្ចាត់ស្មៅត្រូវឱ្យចំគោលដៅ ជៀសវាងប៉ះពាល់ដល់តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។ |
| ៥. វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់ស្មៅគឺយោងទៅតាមសេចក្តីណែនាំស្លាកផលិតផល ចន្លោះពេលប្រមូលផល និងមិនលើសពីកម្រិតប្រើប្រាស់ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ) ។ |
| ៦. ការជ្រើសរើស និងប្រើប្រាស់ថ្នាំកម្ចាត់ស្មៅត្រូវឱ្យចំប្រភេទស្មៅគោលដៅ ពិចារណាលើការកំណត់ពេលវេលាសមស្រប និងពិនិត្យលើភាពស៊ាំនៃថ្នាំ (សម្រាប់ប្រសិទ្ធភាព)។ |

## R18.1. ការគ្រប់គ្រងស្មៅស្រែ

| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) គ្មានការប្រើប្រាស់វិធីសាស្ត្រកម្ចាត់ស្មៅ (បន្ទាប់ពីប្រើប្រាស់វិធីសាស្ត្របង្ការកុំឱ្យមានស្មៅ)។ | ៣ |
| វិធីសាស្ត្រកម្ចាត់ស្មៅត្រូវបានអនុវត្ត | |
| b) កសិករគ្រប់គ្រងស្មៅយ៉ាងមានប្រសិទ្ធភាព ដោយមិនប្រើប្រាស់ថ្នាំគីមីកម្ចាត់ស្មៅ។ | ៣ |
| c) កសិករអនុវត្តតាមគោលការណ៍ IPM ទាំង ៦ ដូចបានបង្ហាញ។ | ៣ |
| កសិករអនុវត្តគោលការណ៍ IPM ចំនុច ១, ២, ៣, ៤ និង៥ ប៉ុណ្ណោះ។ | ២ |
| កសិករអនុវត្តគោលការណ៍ IPM ចំនុច ១, ២, និង ៣ ប៉ុណ្ណោះ។ | ១ |
| កសិករមិនបានអនុវត្ត គោលការណ៍ ១,២ និង ៣។ | ០ |

# ផ្នែកទី៥

## ការគ្រប់គ្រងសមាសភាពចម្រុះ (IPM) (ត)

### វិធានការបង្ការការគ្រប់គ្រងស្មៅចង្រៃដែលត្រូវអនុវត្តរួមមាន៖

- ការរៀបចំដីឲ្យបានល្អ
- ការប្រើប្រាស់គ្រាប់ពូជសុទ្ធល្អ (មានបញ្ជាក់)
- ការដាំដំណាំបង្វិល
- ការពន្លិចទឹកដីស្រែ (ប្រសិនបើមានទឹកច្រើន)





## R18.2. ការគ្រប់គ្រងសត្វល្អិតចង្រៃ

| លក្ខខណ្ឌតម្រូវ៖ កសិករអនុវត្តតាមគោលការណ៍ IPM និងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម |
|---|
| ១. វិធីសាស្ត្រការពារកុំឱ្យមានសត្វល្អិតចង្រៃត្រូវបានប្រើ មុនពេលពិចារណាលើវិធីសាស្ត្រកម្ចាត់ផ្សេងទៀត។ |
| ២. ថ្នាំសំលាប់សត្វល្អិតត្រូវបានប្រើលុះត្រាតែវិធីសាស្ត្រកម្ចាត់ដទៃទៀត (ឧ. សារធាតុទាក់ទាញសត្វល្អិត ភ្នាក់ងារជីវសាស្ត្រ) មិនមានប្រសិទ្ធភាព ហើយកម្រិតបំផ្លាញលើសដែនកំណត់ ឬវត្តមានសត្វល្អិតបំផ្លាញមានច្រើន និងបណ្តាលឱ្យខូចខាតដំណាំធ្ងន់ធ្ងរ។ |
| ៣. ថ្នាំសំលាប់សត្វល្អិតវិសាលគមមិនត្រូវបានប្រើទេ ក្នុងរយៈពេល ៤០ ថ្ងៃដំបូង បន្ទាប់ពីដាំ (លុះត្រាតែអនុលោមតាមជាមួយនឹងការណែនាំ IPM ដែលបានផ្តល់ដោយអ្នកជំនាញ។ |
| ៤. ការជ្រើសរើសថ្នាំសំលាប់សត្វល្អិតចង្រៃគឺសមស្របតាមការណែនាំរបស់រដ្ឋាភិបាល ហើយបានចុះបញ្ជីសម្រាប់ប្រើលើស្រូវ, បានមកពីប្រភពមិនក្លែងក្លាយ និងមិនមាននៅក្នុងបញ្ជីអន្តរជាតិដូចខាងក្រោម៖<br>✓ ការបំពុលដោយសារធាតុគីមីសរីរាង្គ (POP) ដូចមាននៅក្នុងអនុសញ្ញាស្តុកខុម (Stockholm Convention)<br>✓ 1A ឬ B1 ក្នុងចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក<br>✓ ឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញារ៉ូទ័រដាំ (Rotterdam Convention) |
| ៥. ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតចង្រៃត្រូវឱ្យចំគោលដៅ ជៀសវាងប៉ះពាល់ដល់តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។ |
| ៦. វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់សត្វល្អិតចង្រៃគឺយោងទៅតាមសេចក្តីណែនាំស្លាកផលិតផល ចន្លោះពេលប្រមូលផល និងមិនលើសពីកម្រិតប្រើប្រាស់ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ) ។ |
| ៧. ការជ្រើសរើស និងប្រើថ្នាំសំលាប់សត្វល្អិតត្រូវឆ្លើយតបទៅនឹងប្រភេទសត្វល្អិតគោលដៅ ការកំណត់ពេលវេលាសមស្រប និងពិចារណាលើព័ត៌មានក្នុងស្រុកស្តីពីសត្វល្អិតដែលស៊ាំនឹងថ្នាំកម្ចាត់សត្វល្អិត (សម្រាប់ប្រសិទ្ធភាព)។ |

## R18.2. ការគ្រប់គ្រងសត្វល្អិតចង្រៃ

| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) គ្មានប្រើវិធីសាស្ត្រកម្ចាត់សត្វល្អិតចង្រៃទេ | ៣ |
| វិធីសាស្ត្រកម្ចាត់សត្វល្អិតចង្រៃត្រូវបានប្រើហើយ៖ | |
| b) កសិករគ្រប់គ្រងសត្វល្អិតយ៉ាងមានប្រសិទ្ធភាពដោយគ្មានប្រើថ្នាំសំលាប់សត្វល្អិត។ | ៣ |
| c) កសិករអនុវត្តតាមគោលការណ៍ទាំង ៧។ | ៣ |
| a) កសិករអនុវត្តតាមគោលការណ៍ ១, ២, ៣, ៤, ៥ និង ៦ ប៉ុណ្ណោះ ។ | ២ |
| a) កសិករអនុវត្តតាមគោលការណ៍ ១, ២, ៣ និង ៤ ប៉ុណ្ណោះ។ | ១ |
| កសិករមិនបំពេញតាមគោលការណ៍ ១, ២, ៣ និង ៤ ទេ ។ | ០ |

# ផ្នែកទី៥

## ការគ្រប់គ្រងសមាសភាពចង្រៃ (IPM) (ត)

### វិធានការបង្ការសត្វល្អិតចង្រៃដែលត្រូវអនុវត្តរួមមាន៖

- ប្រើប្រាស់សារធាតុចិញ្ចឹមឱ្យមានតុល្យភាព (ឧ.ជៀសវាងប្រើជីអាសូតលើសកម្រិត)
- លើកកំពស់នូវសត្រូវធម្មជាតិមានប្រយោជន៍ (ឧ. សត្វល្អិតមានប្រយោជន៍  ពីងពាង) និង បង្កើនជម្រកជីវចម្រុះនៅជុំវិញវាលស្រែ

ប្រើប្រាស់ពូជស្រូវធន់នឹងសត្វល្អិតចង្រៃ

- ដាំដុះស្រូវឱ្យស្របពេលគ្នា
- ប្រើប្រាស់ពូជស្រូវធន់នឹងសត្វល្អិត
- លើកកំពស់ប្រភេទប្រេដាក់ទ័រផ្សេងទៀតដូចជា បក្សី ប្រចៀវ និងពពួកកង្កែប
- ដាំដំណាំបង្វិល ឬពន្យាររយៈពេលដាំដុះបន្ទាប់( ជៀសវាងការផ្ទុះកត្តាចង្រៃ)





# ផ្នែកទី៥

## ការគ្រប់គ្រងសមាសភាពជម្រៃ (IPM) (ត)

### R18.3. ការគ្រប់គ្រងជំងឺ

| លក្ខខណ្ឌតម្រូវ៖ កសិករអនុវត្តតាមគោលការណ៍ IPM និងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម |
|---|
| ១. វិធីសាស្ត្រការពារកុំឱ្យមានជំងឺត្រូវបានប្រើ មុនពេលពិចារណាលើវិធីសាស្ត្រកម្ចាត់ផ្សេងទៀត។ |
| ២. ថ្នាំកម្ចាត់ជំងឺផ្សិតត្រូវបានប្រើលុះត្រាតែវិធីព្យាបាលដទៃទៀត (ឧ. ការប្រើភ្នាក់ងារជីវសាស្ត្រ) មិនមានប្រសិទ្ធភាព និងជំងឺមានភាពធ្ងន់ធ្ងរត្រូវបានគេរំពឹងថានឹងបណ្តាលឱ្យខូចខាតឬបាត់បង់យ៉ាងខ្លាំង។ |
| ៣. ការជ្រើសរើសថ្នាំកម្ចាត់ផ្សិតគឺស្របនឹងអនុសាស្ត្ររបស់រដ្ឋាភិបាល និងជាថ្នាំបានចុះបញ្ជីត្រឹមត្រូវ មិនមែនពីប្រភពក្លែងបន្លំ ហើយមិនមាននៅក្នុងបញ្ជីអន្តរជាតិដូចខាងក្រោម៖<br>✓ ការបំពុលដោយសារធាតុគីមីសរីរាង្គ (POP) ដូចមាននៅក្នុងអនុសញ្ញាស្តុកខុម<br>✓ A1 ឬ B1 ក្នុងចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក<br>✓ ឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញារ៉ូទែរដាំ។ |
| ៤. ការប្រើប្រាស់ថ្នាំកម្ចាត់ផ្សិតត្រូវឱ្យចំគោលដៅ ជៀសវាងប៉ះពាល់ដល់តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។ |
| ៥. វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់ផ្សិតត្រូវអនុវត្តតាមការណែនាំលើផ្លាកផលិតផល ចន្លោះពេលប្រមូលផល ឬទុករយៈពេល៣០ថ្ងៃមុនពេលប្រមូលផល មិនប្រើប្រាស់លើកម្រិតណែនាំ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ)។ |
| ៦. ថ្នាំកម្ចាត់ផ្សិតត្រូវប្រើឱ្យចំប្រភេទជម្ងឺ ដោយពិចារណាលើប្រវត្តិថ្មីនៃជម្ងឺបង្កដោយផ្សិត និងព្យាករណ៍លក្ខណៈអាកាសធាតុ និងព័ត៌មានជម្ងឺដែលស៊ាំនឹងថ្នាំកម្ចាត់ផ្សិតនៅក្នុងមូលដ្ឋាន (សម្រាប់ប្រសិទ្ធភាព)។ |

## R18.3. ការគ្រប់គ្រងជំងឺ

| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) មិនតម្រូវឱ្យមានវិធីសាស្ត្រកម្ចាត់ជំងឺដោយប្រើថ្នាំទេ។ | ៣ |
| វិធីសាស្ត្រកម្ចាត់ជំងឺត្រូវបានប្រើហើយៈ | |
| b) កសិករគ្រប់គ្រងជម្ងឺយ៉ាងមានប្រសិទ្ធភាដោយគ្មានការប្រើថ្នាំកម្ចាត់ផ្សិត។ | ៣ |
| c) កសិករអនុវត្តតាមគោលការណ៍ទាំង ៦ចំនុច។ | ៣ |
| d) កសិករអនុវត្តតាមគោលការណ៍ទី ១, ២, ៣, ៤និង ៥ ។ | ២ |
| e) កសិករអនុវត្តតាមគោលការណ៍ទី ១ ២ និង៣។ | ១ |
| f) កសិករមិនអនុវត្តតាមគោលការណ៍ទី ១, ២ និង៣។ | ០ |

# ផ្នែកទី៥

## ការគ្រប់គ្រងសមាសភាពចង្រៃ (IPM) (ត)

វិធីសាស្ត្រគ្រប់គ្រងការពារជម្ងឺរួមមាន( មានប្រសិទ្ធភាពសម្រាប់ដោយផ្សិត បាក់តេរី និងវីរុស)៖

- ប្រើប្រាស់សារធាតុចិញ្ចឹមឱ្យមានតុល្យភាព (ឧ.ជៀសវាងប្រើជីអាសូតលើសកម្រិត)
- ដុះដុះដោយមានដង់ស៊ីតេដំណាំសមស្រប
- ប្រើប្រាស់ពូជស្រូវធន់
- ដាំដុះស្រូវឱ្យស្របពេលគ្នា
- ដករុក្ខជាតិជាជំរកចេញ (ស្មៅចង្រៃនៅលើភ្លឺ ស្រូវម្សូរ ឬស្រូវដុះខ្លួនឯង) ជាប្រភពចម្លងជំងឺ
- រក្សាបរិស្ថានល្អរវាងដី និងគម្របរបស់ដំណាំ ទាំងលក្ខខណ្ឌស្ងួត ឬសើម (អាស្រ័យលើប្រភេទជម្ងឺ)



## R18.4. ការគ្រប់គ្រងសិប្បីសត្វ (ពពួកខ្យង)

| លក្ខខណ្ឌតម្រូវ៖ កសិករអនុវត្តតាមគោលការណ៍ IPM និងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម |
|---|
| ១. វិធីសាស្ត្រការពារពពួកខ្យងត្រូវបានប្រើ មុនពេលជ្រើសរើសវិធីសាស្ត្រកម្ចាត់ពពួកខ្យង។ |
| ២. ថ្នាំកម្ចាត់ពពួកខ្យងត្រូវបានប្រើ តែប្រសិនបើវិធីសាស្ត្រកម្ចាត់ផ្សេង (ឧ. ប្រមូល) មិនមានប្រសិទ្ធភាព ហើយវត្តមានសត្វបំផ្លាញលើលកម្រិត ដែលបណ្ដាលឱ្យប៉ះពាល់ខ្លាំង។ |
| ៣. ការជ្រើសរើសថ្នាំកម្ចាត់ពពួកខ្យងគឺស្របនឹងអនុសាស្ត្ររបស់រដ្ឋាភិបាល និងជាថ្នាំបានចុះបញ្ជីត្រឹមត្រូវ សម្រាប់ប្រើប្រាស់ក្នុងស្រូវដែលបានមកពី៖<br>- មិនមែនពីប្រភពក្លែងបន្លំ<br>- ហើយមិនមាននៅក្នុងបញ្ជីអន្តរជាតិដូចជា (POP) , A1 ឬ B1 និង ឧបសម្ព័ន្ធទី ៣។ |
| ៤. ការប្រើប្រាស់ថ្នាំកម្ចាត់ពពួកខ្យងត្រូវឱ្យចំគោលដៅ ជៀសវាងប៉ះពាល់ដល់តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។ |
| ៥. វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់ពពួកខ្យងត្រូវអនុវត្តតាមការណែនាំលើផ្លាកផលិតផល មិនត្រូវប្រើមុនពេលស្ទូងដោយដៃទេ ទុកចន្លោះពេលប្រមូលផល និងមិនប្រើប្រាស់លើកម្រិតណែនាំ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ)។ |
| ៦. ថ្នាំកម្ចាត់ពពួកខ្យងត្រូវប្រើឱ្យចំប្រភេទសិប្បីសត្វ និងត្រូវប្រើប្រាស់តែនៅរយៈពេល៣ សប្ដាហ៍ដំបូងបន្ទាប់ពីការដាំដុះដំណាំ។ |

# R18.4. ការគ្រប់គ្រងសិប្បីសត្វ (ពពួកខ្យង)

| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) មិនតម្រូវឱ្យមានវិធីសាស្ត្រកម្ចាត់ពពួកខ្យងដោយប្រើថ្នាំទេ។ | ៣ |
| តម្រូវឲ្យមានវិធីសាស្ត្រគ្រប់គ្រងពពួកខ្យងដែលមាន៖ | |
| b) កសិករគ្រប់គ្រងពពួកខ្យងយ៉ាងមានប្រសិទ្ធភាពដោយគ្មានការប្រើថ្នាំកម្ចាត់ពពួកខ្យង។ | ៣ |
| c) កសិករអនុវត្តតាមគោលការណ៍ទាំង ៦ចំនុច។ | ៣ |
| d) កសិករអនុវត្តបានតែគោលការណ៍ទី ១, ២, ៣, ៤និង ៥ ប៉ុណ្ណោះ។ | ២ |
| e) កសិករអនុវត្តបានតែគោលការណ៍ទី ១ ២ និង៣ប៉ុណ្ណោះ។ | ១ |
| f) កសិករមិនអនុវត្តតាមគោលការណ៍ទី ១, ២ និង៣។ | ០ |

# ផ្នែកទី៥

## ការគ្រប់គ្រងសមាសភាពចង្រៃ (IPM) (ត)

**វិធីសាស្ត្រគ្រប់គ្រងពពួកខ្យងដោយមិនប្រើសារធាតុគីមីមាន៖**

- ការគ្រប់គ្រងបែបរូបសាស្ត្រ (ការបំផ្លាញពង ការរើសខ្យងខ្ចៅដោយដៃ)
- បន្ថយកំពស់ទឹកនៅដំណាក់កាលលូតលាស់ដំបូង ប្រើប្រាស់ពូជស្រូវធន់
- ប្រើប្រាស់ និងជំរុញឱ្យមានពពួកប្រេដាក់ទ័រ (ឧ. បក្សីព្រៃ ទា និងត្រី)
- ប្រើប្រាស់សំណាបចាស់សម្រាប់ស្ទូងដោយសាបមិនញឹកពេក និង ស្ទូងសំណាបចាស់)
- ឆ្លាស់មុខដំណាំឬទុកចន្លោះពេលមិនដាំដុះយូរជាងមុន។



## R18.5. ការគ្រប់គ្រងសត្វកណ្ដុរ

| លក្ខខណ្ឌតម្រូវ៖ កសិករអនុវត្តតាមគោលការណ៍ IPM និងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម |
|---|
| ១. វិធីសាស្ត្រគ្រប់គ្រងកណ្ដុរត្រូវបានប្រើ មុនពេលជ្រើសរើសវិធីសាស្ត្រកម្ចាត់កណ្ដុរ។ |
| ២. ថ្នាំកម្ចាត់កណ្ដុរត្រូវបានប្រើ ប្រសិនបើវិធីសាស្ត្រកម្ចាត់ផ្សេង (ឧ. ដាក់អន្ទាក់ ប្រមាញ់) មិនមានប្រសិទ្ធភាព ឬមានប្រវត្តិបញ្ហាសត្វកណ្ដុរបំផ្លាញ និងមានវត្តមានសត្វកណ្ដុរច្រើនអាចបណ្ដាលឱ្យមានការបំផ្លាញធ្ងន់ធ្ងរ។ |
| ៣. ការជ្រើសរើសថ្នាំកម្ចាត់កណ្ដុរគឺស្របនឹងអនុសាស្ត្ររបស់រដ្ឋាភិបាល និងជាថ្នាំបានចុះបញ្ជីត្រឹមត្រូវ សម្រាប់ប្រើប្រាស់ក្នុងស្រូវដែលបានមកពី៖<br>- មិនមែនពីប្រភពក្លែងបន្លំ<br>- ហើយមិនមាននៅក្នុងបញ្ជីអន្តរជាតិដូចជា (POP) , A1 ឬ B1 និង ឧបសម្ព័ន្ធទី ៣។ |
| ៤. ការប្រើប្រាស់ថ្នាំកម្ចាត់កណ្ដុរត្រូវឱ្យចំគោលដៅ ជៀសវាងប៉ះពាល់ដល់តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។ |
| ៥. វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់កណ្ដុរត្រូវអនុវត្តតាមការណែនាំលើផ្លាកផលិតផល ទុកចន្លោះពេលប្រមូលផល និងមិនប្រើប្រាស់លើសកម្រិតណែនាំ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ)។ |
| ៦. ថ្នាំកម្ចាត់កណ្ដុរត្រូវប្រើឱ្យចំប្រភេទសត្វកណ្ដុរ និងប្រើប្រាស់មុនពេលបង្កបង្កើនផល ជៀសវាងការផ្ទុះការបំផ្លាញនៅក្នុងដំណាក់កាលដាក់គ្រាប់ ហើយគួរដាក់នៅក្រោមគម្របការពារ ឧ. បំពង់ឫស្សី ឬត្រឡោកដូង ដែលបក្សីមិនងាយចូលទៅស៊ីបាន ហើយមិនងាយត្រូវទឹកភ្លៀង (សម្រាប់ប្រសិទ្ធភាព)។ |

## R18.5. ការគ្រប់គ្រងសត្វកណ្តុរ

| កម្រិតនៃការអនុវត្តន៍តាម | |
| --- | --- |
| a) មិនតម្រូវឱ្យមានវិធីសាស្ត្រកម្ចាត់កណ្តុរដោយប្រើថ្នាំទេ។ | ៣ |
| តម្រូវឲ្យមានវិធីសាស្ត្រគ្រប់គ្រងកណ្តុរដែលមាន៖ | |
| b) កសិករគ្រប់គ្រងកណ្តុរយ៉ាងមានប្រសិទ្ធភាពដោយគ្មានការប្រើថ្នាំកម្ចាត់ពពួកខ្យង។ | ៣ |
| c) កសិករអនុវត្តតាមគោលការណ៍ទាំង ៦ចំណុច។ | ៣ |
| d) កសិករអនុវត្តបានតែគោលការណ៍ទី ១, ២, ៣, ៤និង ៥ ប៉ុណ្ណោះ។ | ២ |
| e) កសិករអនុវត្តបានតែគោលការណ៍ទី ១ ២ និង៣ប៉ុណ្ណោះ។ | ១ |
| f) កសិករមិនអនុវត្តតាមគោលការណ៍ទី ១, ២ និង៣។ | ០ |

# ផ្នែកទី៥

## ការគ្រប់គ្រងសមាសភាពចង្រៃ (IPM) (ត)

វិធីសាស្រ្តគ្រប់គ្រងកណ្តុរដោយមិនប្រើសារធាតុគីមីរួមមាន៖

- គ្រប់គ្រងសត្វកណ្តុរជាសហគមន៍ (ឧ. យុទ្ធនាការលុបបំបាត់កណ្តុរ **ដាំ**ដំណាំអន្ទាក់)
- ដាំដុះដំណាំស្របពេលគ្នា
- ធ្វើភ្លឺស្រែឱ្យតូច (កាត់បន្ថយជម្រកកណ្តុរ)
- ថែរក្សាសត្វស៊ីកណ្តុរ (បក្សីស៊ីកណ្តុរ ពស់)។



## R18.6. ការគ្រប់គ្រងសត្វបក្សី

| លក្ខខណ្ឌតម្រូវ |
|---|
| **ជម្រើសការគ្រប់គ្រងបក្សីដោយមិនសម្លាប់មានដូចជា៖**<br>• ដាំដុះស្របពេលគ្នា<br>• ប្រើឧបករណ៍បន្លាច/បំភ័យ (ឧ. ចងធ្វើជាទីមោង, ចងខ្សែកាសែតពណ៌ចាំងភ្លឺ, ធ្វើសំលេងរំខាន ឬ សំណាញ់ ណែ្តញ<br>• ថែរក្សាសត្វមានប្រយោជន៍ ដែលស៊ីបក្សី (ឧ. បក្សីស៊ីសត្វស្លាប បក្សីស្រែក៍(shrikes) កញ្ជ្រោង, តាមរយៈការថែរក្សាជម្រកនិងមិនមានការរំខានពង កូនវាទេ។ |



## R18.6. ការគ្រប់គ្រងសត្វបក្សី



| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) មិនមានបក្សីដែលតម្រូវឲ្យមានគ្រប់គ្រងទេ។ | ៣ |
| តម្រូវឲ្យមានការគ្រប់គ្រងបក្សីនិង៖៖ | |
| b) បក្សីត្រូវបានគ្រប់គ្រងដោយវិធីសាស្រ្តមិនសម្លាប់ | ២ |
| c) បក្សីត្រូវបានគ្រប់គ្រងដោយការដាក់អន្ទាក់រស់ ហើយបក្សីទាំងអស់ត្រូវបានលែងទាំងរស់ទៅវិញ | ២ |
| d) បក្សីត្រូវបានគ្រប់គ្រងដោយការប្រមាញ់ដោយរើសប្រភេទសត្វបំផ្លាញ។ | ១ |
| f) បក្សីត្រូវបានសម្លាប់មិនរើសមុខ។ | ០ |

# ផ្នែកទី៦

## ការប្រមូលផល និងក្រោយប្រមូលផល



ស្តង់ដា SRP លើការប្រមូលផល និងក្រោយប្រមូលផលមាន ៦ លក្ខខណ្ឌតម្រូវគឺ៖

R19. កំណត់ពេលវេលាប្រមូលផល

R20. ឧបករណ៍ប្រមូលផល

R21. ពេលវេលាហាលសម្ងួត

R22. បច្ចេកទេសហាលសម្ងួត

R23. ការទុកដាក់ស្រូវ

R24. ជញ្ជាំងស្រូវ

R25, ចំបើង

# ផ្នែកទី៦

## ការប្រមូលផល និងក្រោយប្រមូលផល (ត)

ហេតុអ្វីបានជាការអនុវត្តការប្រមូលផល និងក្រោយប្រមូលផលមានសារៈសំខាន់?

- បង្កើនគុណភាពនៃគ្រាប់ស្រូវតាមរយៈពេលវេលានិងវិធីសាស្ត្រច្បាស់លាស់។
- ជួយកាត់បន្ថយការបាត់បង់ស្បៀងអាហាររហូតដល់ ២០% ដោយសារការបាត់បង់ក្រោយប្រមូលផល ពេលសម្ងួត ការស្តុកទុក ការដឹកជញ្ជូន។
- ជួយកាត់បន្ថយការបំភាយឧស្ម័នមេតានពីសំណល់ដែលមិនរលួយហើយលិចទឹក (ចំបើងនិងចំបើង) ក្នុងការដាំដុះស្រូវ។



## R19. កំណត់ពេលវេលាប្រមូលផល

**Elements for timing of harvest indicator**

**1**

| Color of Grains per Panicle |
|---|
|  80-85% are straw – or yellow- color |

**2**

| Moisture Content |
|---|
|  between 21-24% |

**3**

| Number of days after heading | |
|---|---|
| 28 – 35 days in DRY season | 32 – 38 days in WET season |

**4**

| Number of days after sowing | | |
|---|---|---|
| 130 – 136 days for late-maturing varieties | 113 – 125 days for medium-maturing varieties | 110 days for early-maturing varieties |

**5**

| Hardness of the lower parts of the panicle |
|---|
|  "hard-dough" stage (firm but not brittle) |

## R19. កំណត់ពេលវេលាប្រមូលផល

| លក្ខខណ្ឌតម្រូវ | កម្រិតនៃការអនុវត្តន៍តាម | |
|---|---|---|
| ដំណាំស្រូវត្រូវបានប្រមូលផលតាមពេលវេលាសមស្រប ដើម្បីបង្កើនគុណភាពគ្រាប់ស្រូវជាអតិបរមា<br>**ការណែនាំទូទៅក្នុងការកំណត់ពេលវេលាសមស្របប្រមូលផល**<br>១. គ្រាប់ស្រូវមានសភាពក្នុរស្រូវទុំពី ៨០-៨៥%មានពណ៌លឿង ឬ ដូចចំបើង<br>២. គ្រាប់ស្រូវមានអត្រាសំណើមចន្លោះពី២១% ទៅ ២៤%<br>៣. គ្រាប់ស្រូវទុំនៅចន្លោះពី២៨ និង៣៥ថ្ងៃបន្ទាប់ពីចេញផ្កា ចំពោះរដូវប្រាំង និងចន្លោះពី៣២ ទៅ៣៨ថ្ងៃបន្ទាប់ពីចេញផ្កា ចំពោះរដូវវស្សា<br>៤. ចន្លោះពី១៣០ ទៅ១៣៦ថ្ងៃបន្ទាប់ពីព្រួសសម្រាប់ពូជស្រូវធ្ងន់ ចន្លោះ១១៣ ទៅ១២៥ថ្ងៃសម្រាប់ពូជស្រូវកណ្តាល និង១១០ថ្ងៃ សម្រាប់ប្រភេទពូជស្រូវស្រាល។<br>៥. គ្រាប់ស្រូវនៅគល់ក្នុរមានសភាពរឹង ដំណាក់កាល (រឹងប៉ុន្តែមិនងាយបាក់) មិននៅជាក់ម្សៅ ឬទឹកដោះ។ | a) កសិករអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី១ ឬ ២។ | ៣ |
| | b) កសិករអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី៣ ឬ ៤។ | ២ |
| | c) កសិករអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី៥។ | ១ |
| | d) មិនបានអនុវត្តតាមខាងលើទាំងអស់ | ០ |

## R20. ឧបករណ៍ប្រមូលផល

| លក្ខខណ្ឌតម្រូវ |
| --- |
| ស្រូវត្រូវបានប្រមូលផលដោយឧបករណ៍ស្អាត ដើម្បីការពារកុំឲ្យមានការចម្លងជំងឺ និងការលាយចូលប្រភេទពូជស្រូវផ្សេងទៀត។<br>ក្នុងករណីប្រើប្រាស់ម៉ាស៊ីនច្រូត ត្រូវមានការកែតម្រូវ កំណត់ និងដំណើរការឲ្យបានល្អបំផុតដោយផ្អែកលើប្រភេទដំណាំ និងស្ថានភាពដីស្រែដែលធ្វើយ៉ាងណាឲ្យការបាត់បង់គុណភាព និងការបែកបាក់គ្រាប់ស្រូវនៅសល់ជាអប្បបរមា។ |



| កម្រិតនៃការអនុវត្តន៍តាម | |
| --- | --- |
| សម្រាប់ការប្រមូលផលដោយដៃ | |
| a) ឧបករណ៍ប្រមូលផលត្រូវបានសម្អាតមុនពេលប្រើ។ | ៣ |
| b) ឧបករណ៍ប្រមូលផលមិនត្រូវបានសម្អាតមុនពេលប្រើទេ។ | ០ |
| សម្រាប់ការប្រមូលផលមេកានិច៖ | |
| c) ឧបករណ៍ប្រមូលផលត្រូវបានសម្អាតមុនពេលប្រើប្រាស់ ហើយការកំណត់ម៉ាស៊ីនត្រូវបានកែសម្រួល | ៣ |
| d) ទាំងឧបករណ៍ប្រមូលផលត្រូវបានសម្អាតមុនពេលប្រើប្រាស់ ឬការកំណត់ម៉ាស៊ីនត្រូវបានកែសំរួល។ | ១ |
| e) ឧបករណ៍ប្រមូលផលមិនត្រូវបានសម្អាតមុនពេលប្រើ ហើយការកំណត់ម៉ាស៊ីនមិនត្រូវបានកែតម្រូវ។ | ០ |

**ផ្នែកទី៦**

# ការប្រមូលផល និងក្រោយប្រមូលផល (ត)

## R21. ពេលវេលាហាលសម្ងួត

| លក្ខខណ្ឌតម្រូវ |
|---|
| ការហាលសម្ងួតស្រូវនៅកសិដ្ឋានក្នុងរយៈពេល២៤ម៉ោងក្រោយពេលប្រមូលផល។<br>ត្រូវកត់ត្រាសំណើមចុងក្រោយ ហើយសំណើមគ្រាប់ស្រូវ អាស្រ័យលើការប្រើប្រាស់បន្ទះ<br>- សំណើម១៤-១៨% សម្រាប់ការលក់ដោយផ្ទាល់តែក្នុងរយៈពេល៣ថ្ងៃ<br>- សំណើម១៦% ឬតិចជាង សម្រាប់ការលក់តែម្តងក្នុងរយៈពេល១សប្តាហ៍<br>- សំណើម១៤% ឬតិចជាង សម្រាប់គ្រាប់ស្រូវស្តុកទុកយូរជាង១សប្តាហ៍<br>- សំណើម១២% ឬតិចជាង សម្រាប់គ្រាប់ស្រូវស្តុកទុកធ្វើពូជ<br>សំណើមគ្រាប់ស្រូវគរជាគំនរ មិនអាចលើសពី១% បន្ទាប់ពីហាលសម្ងួតបើប្រៀបធៀបនឹងសំណើមមធ្យម (សំណើមទីជម្រាល) ។<br>ប្រសិនបើមិនហាលសម្ងួតស្រូវនៅកសិដ្ឋានទេ (ឧ. ទីធ្លារចាក់បេតុងរបស់កសិករ) ត្រូវដឹកស្រូវទៅសម្ងួតនៅ (ឧ. រោងម៉ាស៊ីន) ឬ កន្លែងកែច្នៃក្នុងរយៈពេល១២ម៉ោងក្រោយពេលប្រមូលផល។ |

| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) កសិករបានដឹកស្រូវទៅកាន់កន្លែងសម្ងួត ឬកន្លែងកែច្នៃក្នុងរយៈពេល១២ម៉ោងក្រោយពេលប្រមូលផល | ៣ |
| b) កសិករបានចាប់ផ្តើមសម្ងួតនៅកសិដ្ឋានក្នុងរយៈពេល២៤ម៉ោងក្រោយពេលប្រមូលផល ហើយសំណើមហូតដល់ ១៦% ឬតិចជាងនេះ និងសំណើមមិនលើសពី១% សំណើម ជម្រាលក្នុង១សប្តាហ៍។ | ៣ |
| c) កសិករចាប់ផ្តើម សម្ងួតនៅកសិដ្ឋានក្នុងរយៈពេល២៤ម៉ោងក្រោយពេលប្រមូលផល ហើយទុកហូតសំណើម១៤-១៨% ឬតិចជាងនេះ និងសំណើមមិនលើសពី១% សំណើមជម្រាលក្នុងរយៈពេល៣ថ្ងៃ។ | ២ |
| d) កសិករចាប់ផ្តើម សម្ងួតនៅស្រែក្នុងរយៈពេល២៤ម៉ោងក្រោយពេលប្រមូលផល ប៉ុន្តែមិនអាចកត់ត្រាសំណើម១៨% ឬតិចជាងនេះ ឬមិនដល់១% ឬតិចជាងសំណើមទីជម្រាល។ | ១ |
| e) កសិករមិនដឹកស្រូវទៅកន្លែងសម្ងួត ឬកែច្នៃ ក្នុងរយៈពេល១២ម៉ោងបន្ទាប់ពីប្រមូលផលរួម ឬចាប់ផ្តើមហាលស្ងួតស្រូវនៅស្រែក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីប្រមូលផល។ | 0 |

# ផ្នែកទី៦

# ការប្រមូលផល និងក្រោយប្រមូលផល (ត)

## R21. ពេលវេលាហាលសម្ងួត

HARVEST

→ Not dried on farm (direct selling) → Transported to drying facility within 12 hours after harvest

→ Dried on farm




| | |
|---|---|
| 14-18% m.c. | Direct selling |
| ≤16% m.c. | Sell within 3 days |
| ≤ 14% m.c. | Sell within 1 week |
| ≤ 12% m.c. | Store as seeds |

- ✓ *Final moisture content (m.c.) has to be documented!*
- ✓ *Within a batch, the variation of the the m.c. of a grain after drying is not more than 1% compare with the average m.c.*

## R21. ពេលវេលាហាលសម្ងួត

បញ្ជាក់៖ នៅពេលដែលកសិករមិនហាលសម្ងួតគ្រាប់ស្រូវនៅកសិដ្ឋានទេ
ដូច្នេះលក្ខខណ្ឌតម្រូវទី ២២ និង ២៣ មិនត្រូវអនុវត្តបានឡើយ។
រំលងទៅលក្ខខណ្ឌតម្រូវទី ២៤។



## R22. បច្ចេកទេសហាលសម្ងួត

| លក្ខខណ្ឌតម្រូវ |
|---|
| ស្រូវត្រូវបានសម្ងួតដោយប្រើបច្ចេកទេសសម្ងួតប្រកបដោយនិរន្តរភាព។ |
| **សម្រាប់ហាលសម្ងួតដោយកំដៅថ្ងៃ៖** |
| ១. កម្រាស់ស្រទាប់គឺ២-៤ស.មនិង<br>២. ស្រូវគឺត្រូវប្រែត្រឡប់អោយបានទៀងទាត់<br>៣. ការពារគ្រាប់ស្រូវកុំឲ្យប៉ះទឹកភ្លៀង<br>៤. គ្រាប់ស្រូវត្រូវការពារពីជំងឺផ្សិ )មីកូតុកស៊ីន (ការជាន់របស់មនុស្ស សត្វ លើ(ឧ. សៃ្ស កន្ទេល ផ្ទាំង តង់)។ |
| **សម្រាប់ការសម្ងួតដោយម៉ាស៊ីន៖** |
| ៥. ប្រើប្រាស់ឡសម្ងួត ដែលបានបញ្ជាក់គុណភាព ដើម្បីផលិតគ្រាប់ស្រូវមានគុណភាពល្អបំផុត (មិនប្រែពណ៌ មិនបាត់ក្លិន មានអត្រាគ្រាប់អង្ករបាក់ទាប់បំផុត)។<br>៦. កំណត់ម៉ាស៊ីនសម្ងួតនៅសីតុណ្ហភាពអតិបរិមា ៤៣ អង្សាសេសម្រាប់ម៉ាស៊ីនសម្ងួតផ្តេកនិង ៥៥ អង្សាសេសម្រាប់ដំណើរការម៉ាស៊ីនសម្ងួតវិលជុំ។ |

| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) មិនមានការសម្ងួតដោយខ្លួនគាត់ឯងទេ។ | គ្មាន |
| b) កសិករប្រើម៉ាស៊ីនសម្ងួតអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី៥ និង៦។ | ៣ |
| c) សម្ងួតដោយកំដៅថ្ងៃដោយអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី១,២,៣ និង៤។ | ២ |
| d) សម្ងួតដោយកំដៅថ្ងៃដោយអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី៣ និង៤។ | ១ |
| e) មិនបានអនុវត្តតាមលក្ខណៈវិនិច្ឆ័យទាំងអស់។ | 0 |

# ផ្នែកទី៦ ការប្រមូលផល និងក្រោយប្រមូលផល (ត)

## R23. ការទុកដាក់ស្រូវ

| លក្ខខណ្ឌតម្រូវ |
|---|
| ស្រូវត្រូវបានស្តុកទុកយ៉ាងមានសុវត្ថិភាពរក្សាគុណភាពតាមរយៈការស្តុកបិទជិត ឬ វិធានការខាងក្រោម៖<br>១. ការពារការចម្លងសារសារធាតុគ្រោះថ្នាក់ ដូចជាកសិគីមី<br>២. រក្សាសំណើមគ្រាប់ស្រូវ១៤% ឬ តិចជាង<br>៣. ជៀសវាងធ្វើឲ្យគ្រាប់ស្រូវសើមឡើងវិញ<br>៤. ការពារការបំផ្លាញពីសត្វល្អិតចង្រៃ ដោយមិនចាំបាច់ធ្វើភូតគមអនាម័យ )បាញ់ ឬដាក់ថ្នាំ<br>៥. គ្រាប់ស្រូវត្រូវបានសម្អាតមុនពេលស្តុកទុក (សំអាតចេញកាកសំណល់ គ្រាប់ស្មៅ និងសត្វល្អិតចេញ)។ |



| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) កសិករមិនទុកដាក់ស្រូវនៅកសិដ្ឋានទេ។ | គ្មាន |
| b) កសិករអនុវត្តទុកដាក់បិទជិត ឬ អនុលោមវិធានការទាំង៥។ | ៣ |
| c) កសិករអនុវត្តតាមតែវិធានការលេខ១, ២,៣ និង៤ប៉ុណ្ណោះ។ | ២ |
| d) កសិករអនុវត្តវិធានការតាមតែលេខ១ និង២ប៉ុណ្ណោះ។ | ១ |
| e) មិនមែនអនុវត្តតាមវិធានការខាងលើទេ។ | ០ |

## R24. ជញ្ជ្រាំងស្រូវ

| លក្ខខណ្ឌតម្រូវ |
|---|
| ជញ្ជ្រាំងស្រូវត្រូវបានគ្រប់គ្រងតាមវិធីប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងដើម្បីរក្សាឬកែលម្អគុណភាពដី។<br><br>ជញ្ជ្រាំងស្រូវ៖<br>១. មិនត្រូវដុត<br>២. រក្សាទុកបានសមស្រប យ៉ាងតិចឱ្យបាន៣សប្តាហ៍ដើម្បីឲ្យរលួយពុកផុយមុនពេលបញ្ចូលទឹក។ |




| កម្រិតនៃការអនុវត្តន៍តាម | |
|---|---|
| a) កសិករបំពេញតាមលក្ខខណ្ឌទី១ និង២ ដោយមិនភ្ជួរលុបជញ្ជ្រាំងស្រូវចូលក្នុងដី។ | ៣ |
| b) កសិករបំពេញតាមលក្ខខណ្ឌទី១ និង២ ដោយភ្ជួរលុបជញ្ជ្រាំងស្រូវនៅពេលដីស្ងួត។ | ២ |
| c) កសិករបំពេញលក្ខខណ្ឌទី១ ប៉ុន្តែភ្ជួរលុបជញ្ជ្រាំងស្រូវនៅពេលដីលិចទឹក។ | ១ |
| b) កសិករដុតជញ្ជ្រាំងស្រូវ | ០ |

## R25. ចំបើងស្រូវ

| លក្ខខណ្ឌតម្រូវ |
| --- |
| ចំបើងត្រូវបានគ្រប់គ្រងតាមវិធីសាស្ត្រប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងរក្សា ឬបង្កើនជីជាតិឲ្យប្រសើរឡើង។<br>ចំបើងស្រូវគឺ៖<br>១. មិនត្រូវដុត<br>២. រក្សទុកពេលវេលាឲ្យបានគ្រប់គ្រាន់ (យ៉ាងតិចបំផុត២សប្តាហ៍) ដើម្បីឱ្យចំបើងពុកផុយ ប្រសិនបើចំបើងនៅសល់ក្នុងស្រែគឺត្រូវភ្ជួរលុបក្នុងដី<br>៣. ប្រមូលយកទៅធ្វើជាចំណីសត្វ ហើយលាមកសត្វត្រូវយកមកដាក់ក្នុងស្រែវិញ ឬ ប្រមូលធ្វើជីកំប៉ុស្ត៍ហើយយកមកដាក់ក្នុងស្រែវិញ។ |

| កម្រិតនៃការអនុវត្តន៍តាម | |
| --- | --- |
| a) កសិករបំពេញតាមលក្ខខណ្ឌទី១ និង៣។ | ៣ |
| b) កសិករបំពេញលក្ខខណ្ឌទី១ និង២ ប៉ុណ្ណោះ។ | ២ |
| c) កសិករបំពេញលក្ខខណ្ឌទី១ ប៉ុណ្ណោះ។ | ១ |
| d) កសិករដុតចំបើងស្រូវ។ | ០ |

